# ថ្លៃប្រណិត

## *តម្រូវការរបស់ចិននូវគ្រឿងសង្ហារឹមពីឈើក្រហមប្រណិត កំពុងបញ្ឆេះប្រតិបត្តិការរត់ពន្ធឈើរាប់លានដុល្លារក្នុងប្រទេសកម្ពុជា*

ថ្ងៃ សុក្រ ទី 6 ខែ កុម្ភៈ ឆ្នាំ 2015

របាយការណ៍របស់ គ្លូបល វីតណេស ថ្មីមួយបង្ហាញថា ការរក់និយមសង្ហារឹម *ហុងមុ* ពីឈើក្រញូង កំពុងបញ្ឆេះជំនួញឈើខុសច្បាប់ក្នុងផ្សារងងឹតរាប់លានដុល្លារទូទាំងប្រទេសកម្ពុជា។ *ថ្លៃប្រណិត* គឺជាលទ្ធផលនៃការស៊ើបអង្កេតសម្ងាត់រយៈពេលប្រាំបីខែ អំពីការមមាញឹកចំពោះឈើប្រណិតចុងក្រោយរបស់កម្ពុជា។ របាយការណ៍កត់ត្រាអំពីរបៀបដែលមហាសេដ្ឋីកម្ពុជា ឧកញ៉ា ទ្រី ភាព គឺជាអ្នកដឹកនាំនៃបណ្តាញការកាប់ឈើខុសច្បាប់មួយ ដែលផ្អែកលើការសមគំនិតរបស់មន្ត្រីពីរដ្ឋាភិបាល ទាហាន ប៉ូលីស និងគយ ដើម្បីឈ្ងួសឆាយឈើកម្រដូចជា ក្រញូង ជួញឈើដោយលួចលាក់ទូទាំងប្រទេស និងផ្ទុកឈើទាំងនោះលើទូកឆ្ពោះទៅទីក្រុងហុងកុង។

មីហ្គេន មែកខលណេស នៃ គ្លូបល វីតណេស បាននិយាយថា "អ្នកទិញគ្រែបួនជ្រុង និងតុឥតប្រយោជន៍ដ៏មានតម្លៃក្នុងប្រទេសចិន ប្រហែលអាចចំណាយប្រាក់ឥតប្រយោជន៍ដោយមិនដឹងខ្លួន លើអ្វីដែលគ្រាន់តែអាចត្រូវបានពណ៌នាថាជា បងធំឈើ។ ទ្រី ភាព និងបណ្តាញរបស់គាត់ កំពុងបំផ្លិចបំផ្លាញព្រៃឈើចុងក្រោយរបស់ប្រទេសកម្ពុជា និងកំពុងលួចប្លន់សហគមន៍ជនជាតិភាគតិចនូវជីវភាពរស់នៅរបស់ពួកគេ។ ស្របពេលជាមួយគ្នានេះ បណ្តាមន្ត្រីដែលគួរតែកំពុងបញ្ឈប់ពួកគេ បែរជាកំពុងរួមគំនិតដើម្បីធានាថាឈើរត់ពន្ធធ្វើដំណើរដោយសុវត្ថិភាព ហើយត្រូវបាននាំចេញហាក់បីដូចជាឈើស្របច្បាប់។"

ទោះបីជាច្បាប់ដ៏តឹងរ៉ឹងការពារប្រភេទពូជឈើកម្រ និងប្រណិតមានសុពលភាពចាប់តាំងពីឆ្នាំ 2002 ក៏ដោយក៏ក្រុមហ៊ុន ទ្រី ភាព កំពុងតែនាំចេញឈើច្រើនរហូតដល់ 900 ម៉ែត្រគ្រីគុណ ពីកំពង់ផែអន្តរជាតិក្រុងព្រះសីហនុជារៀងរាល់ថ្ងៃ។ ជារួម 85 ភាគរយនៃការនាំចេញឈើរបស់ប្រទេសកម្ពុជា គឺឆ្ពោះទៅប្រទេសចិន ដោយមានកំណើនការនាំចេញឈើ *ហុងមុ* 150 ភាគរយរវាងឆ្នាំ 2013 និង 2014។

ឧកញ៉ា ទ្រី ភាព គឺជាម្នាក់ក្នុងចំណោមមហាសេដ្ឋីដ៏លេចធ្លោបំផុតរបស់ប្រទេសកម្ពុជា ហើយពីមុនគឺជាទីប្រឹក្សាផ្ទាល់នាយករដ្ឋមន្ត្រី ហ៊ុន សែន។ គាត់កាន់កាប់ដីសម្បទានសរុប 29,589 ហិកតា - មួយភាគបួននៃទំហំដីទីក្រុងហុងកុង។ កិច្ចសម្ភាសន៍ជាមួយប្រភពជិតស្និទ្ធក្នុងរដ្ឋាភិបាល និងឧស្សាហកម្ម ដោយរួមទាំងមនុស្សដែលស្ថិតលើបញ្ជីបៀវត្សផ្ទាល់របស់ ទ្រី ភាព បង្ហាញអំពីរបៀបដែលអ្នកកាប់ឈើក្នុងបណ្តាញរបស់គាត់ ត្រូវបានផ្តល់ជូននូវការធ្វើដំណើរដោយសុវត្ថិភាព ត្រូវបានការពារពីការរឹបអូសឈើ ឬការពិន័យដោយ

សារប្រព័ន្ធនៃអំពើពុករលួយចាក់ឬសគល់។ ក្រុមហ៊ុន ទ្រី ភាព ក៏ត្រូវបានផ្តល់ជូនសិទ្ធិផ្តាច់មុខទិញឈើ ដែលបានរឹបអូសដោយភ្នាក់ងារអនុវត្តច្បាប់ ដើម្បីលក់បន្ត និងនាំចេញយកចំណេញ។

ដោយបានបញ្ជាក់ថាជាម្នាក់ក្នុងចំណោមឈ្មួញកណ្តាលរបស់ ទ្រី ភាព លោក ហាម ហ៊ុយ គឺជាឧត្តមសេនីយ៍ផ្កាយពីរកងអង្គរក្ស*កងពលតូចលេខ70* របស់នាយករដ្ឋមន្ត្រី ដែលត្រូវបានបញ្ជាក់ថាគឺជាការទំនាក់ទំនងដ៏ជិតស្និទ្ធរបស់ក្រុមហ៊ុន ជាមួយកងកម្លាំងប្រដាប់អាវុធរបស់ប្រទេសកម្ពុជា។ អ្នកស៊ើបការណ៍ជាច្រើនក៏បានពណ៌នាផងដែរអំពីទំនាក់ទំនងដ៏ជិតស្និទ្ធរបស់មហាសេដ្ឋីនេះ ជាមួយមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើ។

មែកខលណេស បាននិយាយថា "ការវាយប្រហាររបស់ក្រុមហ៊ុន ទ្រី ភាព លើព្រៃឈើចុងក្រោយរបស់កម្ពុជា គឺស្មើនឹងការលួចប្លន់ទាំងកណ្តាលថ្ងៃត្រង់។ ក្រុមហ៊ុនកំពុងរំលោភមាក់ងាយជាទម្លាប់ និងយ៉ាងគឃ្លើនលើច្បាប់ដែលមានបំណងការពារប្រជាជនកម្ពុជា និងប្រព័ន្ធអេកូឡូស៊ីដែលពួកគេពឹងផ្អែកលើ។ នេះគឺជាគំរូមួយផ្សេងទៀតពីប្រទេសកម្ពុជា ស្តីអំពីអំណាចនយោបាយ និងផលប្រយោជន៍អាជីវកម្ម ធ្វើឲ្យចុះខ្សោយសិទ្ធិរបស់ពលរដ្ឋ និងការចាប់ក្តាប់លក់ដុំនូវធនធានធម្មជាតិរបស់ប្រទេស ដោយពួកវរជនកាន់អំណាចរបស់ប្រទេស។"

នៅកំពង់ផែអន្តរជាតិក្រុងព្រះសីហនុរបស់ប្រទេសកម្ពុជា គ្លូបល វីតណេស បានទទួលឯកសារដឹកជញ្ជូនជាច្រើនច្បាប់ សម្រាប់ឈើដែលមានតម្លៃរហូតដល់ 5.6 លានដុល្លារអាមេរិក សម្រាប់ឈើពីរគំនរ ដែលបាននាំចេញដោយក្រុមហ៊ុន ទ្រី ភាព ទៅកាន់ក្រុមហ៊ុន Kin Chung Transportation Company ក្នុងទីក្រុងហុងកុង។ ការស៊ើបអង្កេតអំពីក្រុមហ៊ុននេះបានបង្ហាញថា ក្រុមហ៊ុននេះមានភាគហ៊ុនដើមទុនត្រឹមតែ 2.00 ដុល្លារហុងកុងប៉ុណ្ណោះ និងមិនមានវត្តមានជាសាធារណៈក្នុងឋានៈជាក្រុមហ៊ុនជំនួញឈើមួយឡើយ។ នៅពេលដែលបាននិយាយទៅកាន់ នាយករបស់ក្រុមហ៊ុនបានអះអាងបញ្ជាក់ថាមិនស្គាល់ក្រុមហ៊ុន ទ្រី ភាព ហើយមិនមានយោបល់ពីមូលហេតុដែលក្រុមហ៊ុនរបស់ខ្លួនបានពាក់ព័ន្ធនឹងការនាំចូលនេះ។ គ្លូបល វីតណេស ក៏បានសរសេរលិខិតជូន ឧកញ៉ា ទ្រី ភាព និងឧត្តមសេនីយ៍ ហាម ហ៊ុយ ដោយស្នើសុំយោបល់របស់ពួកគេលើភស្តុតាងដែលបានបង្ហាញជូនក្នុង*ថ្លៃប្រណិត* តែមិនបានទទួលការឆ្លើយតប។

ការស៊ើបអង្កេតទាំងនេះបង្ហាញថា ឈើណាមួយដែលចាកចេញពីប្រទេសកម្ពុជា គួរតែត្រូវបានចាត់ទុកថាមានការសង្ស័យខ្ពស់ ទោះបីជាត្រូវបានរក្សាទុកកុងទេណឺរមានត្រាអនុម័តរបស់រដ្ឋាភិបាលក៏ដោយ។ ឈើរបស់ក្រុមហ៊ុន ទ្រី ភាព ពុំគួរត្រូវបានចាត់ទុកថាស្របច្បាប់ឡើយ ដោយសារៈ

- ក្រុមហ៊ុន និងបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន ពង្រាយកម្មករដែលអមដំណើរដោយភ្នាក់ងារអនុវត្តច្បាប់របស់រដ្ឋាភិបាល ឲ្យស្វែងរក**ឈើកម្រិតប្រណិត**ដូចជា ក្រញូង ដែលរដ្ឋាភិបាលបានហាមប្រាមពីការប្រមូលផល និងការនាំចេញក្នុងឆ្នាំ 2013។ ប្រភេទពូជនេះ ក៏ត្រូវបានការពារក្រោមច្បាប់អន្តរជាតិ ដែលបានចុះបញ្ជីដោយអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិ លើប្រភេទពូជរងគ្រោះថ្នាក់ នៃសត្វ និងរុក្ខជាតិក្នុងព្រៃឆ្នាំ 2013

- ក្រុមហ៊ុនកំពុងធ្វើឲ្យហិនហោចព្រៃក្នុង**ដីសម្បទានសេដ្ឋកិច្ច** - ដែលជាប្រព័ន្ធភតិសន្យាមួយមានបំណងមិនមែនសម្រាប់ការកាប់ឈើ តែសម្រាប់កសិកម្មទ្រង់ទ្រាយធំ។ គ្មានដីសម្បទានណាមួយ

របស់ក្រុមហ៊ុន គួរតែត្រូវបានចាត់ទុកថាស្របច្បាប់ឡើយ ដោយសារពួកគេគ្រប់គ្រងដីព្រៃធំជាងកម្រិតទំហំអតិបរមា និងមិនបានទទួលការប្រឹក្សាសហគមន៍ចាំបាច់។ ដីសម្បទានជិត 20,000 ហិកតាក្នុងឧទ្យានជាតិវីរជ័យ ដែលជាជម្រករបស់ប្រជាជនជនជាតិភាគតិច និងរុក្ខជាតិ ព្រមទាំងប្រភេទពូជសត្វរងគ្រោះថ្នាក់ជាច្រើន ត្រូវបានយកពីក្រុមហ៊ុនវិញដោយរដ្ឋាភិបាលនាចុងឆ្នាំ 2014

- ក្រុមហ៊ុន ក៏កំពុងប្រើប្រាស់អាជ្ញាប័ណ្ណដីសម្បទានរបស់ខ្លួន ដើម្បីឈូសឆាយឈើហួសពីព្រំដែនកំណត់ **លាងឈើមានតម្លៃ និងឈើដែលត្រូវបានការពារ**តំបន់ជុំវិញ

- ក្រុមហ៊ុនកំពុងនាំចេញ **ទម្រង់នៃឈើដែលបានហាមប្រាមសម្រាប់ការនាំចេញ** ដែលមានដូចជាឈើមិនទាន់កែច្នៃ និងឈើអារអង្កត់ផ្ចិតកម្រាស់ក្រាស់ជាង 25 សង់ទីម៉ែត្រ។

មែកខលណេស បានពន្យល់ថា "វិធានការណ៍បន្ទាន់ គឺត្រូវការចាំបាច់ដើម្បីបញ្ចៀសការបំផ្លិចបំផ្លាញកន្លែងរស់នៅរបស់ព្រៃឈើសំខាន់ៗ និងជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានដែលពឹងផ្អែកលើពួកវា។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែពិនិត្យដោះស្រាយជាបន្ទាន់នូវការកាប់ឈើខុសច្បាប់ និងការពារកាន់តែប្រសើរនូវឈើរងគ្រោះថ្នាក់ និងសិទ្ធិរបស់សហគមន៍ដែលពឹងផ្អែកលើព្រៃឈើ។ រដ្ឋាភិបាលក៏ត្រូវចាត់វិធានការណ៍បន្ទាន់ផងដែរដើម្បីស៊ើបអង្កេតភស្តុតាងថា ឧកញ៉ា ទ្រី ភាព និងអ្នកទាំងឡាយដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ ពាក់ព័ន្ធនឹងសកម្មភាពខុសច្បាប់ជាច្រើន។ អាជ្ញាធរក្នុងទីក្រុងហុងកុង និងចិនដីគោក គួរព្យួរការនាំចូលប្រភេទពូជឈើ *ហុងមុ* កម្រទាំងអស់ពីប្រទេសកម្ពុជា និងឧទ្ទេសនាមបញ្ញត្តិច្បាប់ ដែលហាមប្រាមការនាំចូល ជំនួញ និងការកែច្នៃឈើដែលបានប្រមូលផលដោយខុសច្បាប់ ព្រមទាំង ផលិតផលដែលបានពីឈើទាំងនេះ។"

/ចប់

ទំនាក់ទំនង៖
មីហ្គេន មែកខលណេស ប្រធានដឹកនាំយុទ្ធនាការ - ដី +44(0)2074925845 / +44(0)7540891837
mmacinnes@globalwitness.org
អេលីស ហេរីសុន ទីប្រឹក្សាទំនាក់ទំនង +44(0)2074925890 / +44(0)7841338792
aharrison@globalwitness.org